**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 27-May-2016, 08:00
CMS/CFO: Sann Rada

| | |
|---|---|
| សំណុំរឿងលេខ | ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ |
| ភាគីដាក់ឯកសារ | សហមេធាវីរបស់លោក នួន ជា |
| ដាក់ជូន | អង្គជំនុំជម្រះសាលាដំបូង |
| ភាសាដើម | អង់គ្លេស |
| កាលបរិច្ឆេទឯកសារ | ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៦ |

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន

ឈ្មោះមន្ត្រីកត់ត្រា

ហត្ថលេខា

---

## សំណើរបស់ នួន ជា សុំកោះហៅ ប្រាក់ ខន សារជាថ្មី

---

**ដាក់ដោយ ÷**

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ
Victor KOPPE
លីវ សុវណ្ណា
ព្រុំ ផល្លា
Doreen CHEN
Xiaoyang NIE
Marina HAKKOU
Léa KULINOWSKI
DY Socheata

**ផ្ញើជូន ÷**

**សហមេធាវីរបស់ ខៀវ សំផន**

គង់ សំអុន
Anta GUISSÉ

**សហព្រះរាជអាជ្ញា÷**

ជា លាង
Nicholas KOUMJIAN

**សហមេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Marie GUIRAUD

## I. សេចក្ដីផ្ដើម

1. អនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុង សហមេធាវីរបស់លោក នួន ជា (“ក្រុមមេធាវីការពារក្ដី”) សូមដាក់សំណើនេះសុំឲ្យកោះហៅជាថ្មីសាក្សី ប្រាក់ ខន ដើម្បីផ្ដល់សក្ខីកម្មនៅក្នុងវគ្គនៃការជំនុំជម្រះទាក់ទងនឹងមន្ទីរសន្តិសុខស២១ ។

## II. សាវតារ

2. នៅថ្ងៃទី ២៧, ២៨ និងទី២ ខែ ឧសភា ឆ្នាំ ២០១៦ សាក្សី ប្រាក់ ខន បានផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ។ នៅក្នុងអំឡុងពេលការផ្ដល់សក្ខីកម្មក្រុមមេធាវីការពារក្ដីបានស្នើអង្គជំនុំជម្រះសាលាដំបូងឲ្យផ្ដល់ពេលវេលាបន្ថែម ដើម្បីសួរដេញសាក្សី ប្រាក់ ខន ដោយសារបញ្ហាជាច្រើនដែលក្រុមមេធាវីការពារក្ដីចង់សួរដេញដោលជាមួយសាក្សីនេះ[1]។ អង្គជំនុំជម្រះបានបដិសេធសំណើនេះ ហើយបានអនុញ្ញាតឲ្យក្រុមមេធាវីការពារក្ដីនូវពេលវេលាបន្ថែម១៥នាទី ជាការទូរទាត់ចំពោះពេលវេលាដែលត្រូវបានចំណាយនៅក្នុងការពិភាក្សាលើបញ្ហាផ្លូវច្បាប់ ដែលទាក់ទងនឹងការប្រើប្រាស់ “ចម្លើយសារភាព”[2] ។

## III. ច្បាប់ជាធរមាន

### ក. ការកោះហៅសាក្សីសារជាថ្មី

3. វិធានផ្ទៃក្នុងមិនមានចែង នៅក្នុងស្ថានភាពនៃការកោះហៅសាក្សីសារជាថ្មីដើម្បីឲ្យផ្ដល់សក្ខីកម្ម ។ តែតុលាការព្រហ្មទណ្ឌអន្តរជាតិបានបង្កើតយុត្តិសាស្ត្រ ដែលអនុញ្ញាតឲ្យភាគីកោះហៅសាក្សីសារជាថ្មី នៅពេលមូលហេតុល្អត្រូវបានបង្ហាញ[3]។ នៅក្នុងការសម្រេចថាតើមូលហេតុល្អត្រូវបាន

---

[1] ប្រតិចារិតសវនាការថ្ងៃទី២ ខែឧសភា ឆ្នាំ ២០១៦ (ប្រាក់ ខន ពង្រាងប្រតិចារិត) នៅទំព័រ២៧ បន្ទាត់៩-២៤, ទំព័រ ៤៣ បន្ទាត់៨-២២ ។

[2] ប្រតិចារិតសវនាការថ្ងៃទី២ ខែ ឧសភា ឆ្នាំ ២០១៦ (ប្រាក់ ខន ពង្រាងប្រតិចារិត) នៅទំព័រ៤៤ បន្ទាត់៦-១៣ ។

[3] សម្រាប់ការសង្ខេបយុត្តិសាស្ត្រ សូមមើលឧទាហរណ៍*រឿងក្ដីរដ្ឋអាជ្ញា តទល់ Karadžić,* សេចក្ដីសម្រេចលើញត្តិរបស់ជនជាប់ចោទសុំហៅសារជាថ្មីនូវសាក្សី KDZ080 និង សុំវិកតិភេទនៃវិធានការការពារ” សំណុំរឿងលេខ IT-95-5/18-T ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៣ នៅកថាខណ្ឌ១០ ។ អត្ថបទសាធារណៈ (កោសលុប) នៃសេចក្ដីសម្រេចនេះអាចរកបាននៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៥ ។

បង្ហាញដែរ ឬយ៉ាងណា អង្គជំនុំជម្រះត្រូវពិចារណា "គោលបំណងរបស់ភស្តុតាងដែលភាគីស្នើសុំរំពឹងទាញយកពីសាក្សី ក៏ដូចជាមូលហេតុរបស់ភាគីសម្រាប់ការមិនចំរាញ់យកភស្តុតាងនោះ នៅពេលសាក្សីបានផ្តល់សក្ខីកម្មពីដំបូង"[4]។ ដោយគិតគូរពីសិទ្ធិរបស់ជនជាប់ចោទក្នុងការ ទទួលបានការជំនុំជម្រះដោយគ្មានអូសបន្លាយ ព្រមទាំងការចំណាយរបស់តុលាការ តុលាការព្រហ្មទណ្ឌអន្តរជាតិបានយល់ឃើញថា សំណើសុំកោះហៅសាក្សីសារជាថ្មី "មិនត្រូវអនុញ្ញាតក្នុងកម្រិតតូចនោះទេ និងតែនៅពេលណាដែលភស្តុតាងមានតំលៃភវនីយភាពជាក់លាក់ និងមិនមានចរិតលក្ខណៈជាភស្តុតាងត្រួតគ្នាប៉ុណ្ណោះ"[5] ។

## ខ. ការពិចារណាឡើងវិញ

4. ការពិចារណាឡើងវិញដោយអង្គជំនុំជម្រះទៅលើសេចក្តីសម្រេចរបស់ខ្លួន មិនមានចែងនៅក្នុងវិធានផ្ទៃក្នុងឡើយ។ យ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ខ្លួននឹងដោះស្រាយចំពោះសំណើសុំឲ្យពិចារណាឡើងវិញ "នៅពេលដែលសំណើថ្មី មានកាលៈទេសៈថ្មី ធ្វើជាយុត្តិកម្ម"[6]។ អង្គបុរេជំនុំជម្រះ ដោយអនុវត្តតាមយុត្តិសាស្ត្រដែលមានស្រាប់ពីតុលាការ ICTY បានអនុវត្តលក្ខណវិនិច្ឆ័យទូលាយជាង ដោយសម្រេចថា សិទ្ធិអំណាចរបស់អង្គជំនុំជម្រះក្នុងការពិចារណាឡើងវិញលើសេចក្តីសម្រេចរបស់ខ្លួន អនុវត្តមិនត្រឹមតែក្នុងករណីដែលមាន"ការផ្លាស់ប្តូរកាលៈទេសៈ" (ដែលអាចបណ្តាលមកពី "អង្គហេតុថ្មី ឬទឡ្ហីករណ៍ថ្មី"[7]) ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងក្នុងករណីដែលអង្គជំនុំជម្រះ "សម្រេចថា សេចក្តីសម្រេចកន្លងមកគឺមានកំហុសឆ្គង ឬអាច

---

[4] ដូចខាងលើ ។

[5] ដូចខាងលើ ។

[6] ឯកសារ **E238/11/1**, "សេចក្តីសម្រេចលើសំណើរបស់ អៀង សារី សុំឲ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាឡើងវិញចំពោះសេចក្តីសម្រេចរបស់ខ្លួនដែលថា អៀង សារី មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ និងសំណើសុំបន្ថែម", ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១២, កថាខណ្ឌ ៧។

[7] *សំណុំរឿង ០០១*, ឯកសារ **D99/3/41**, "សេចក្តីសម្រេចលើពាក្យសុំការពិចារណាឡើងវិញចំពោះសេចក្តីសម្រេចស្តីពីការដាក់ពាក្យសុំនៅក្នុងសំណុំរឿង ឌុច", សំណុំរឿង ០០១/១៨-០៧-២០០៧-អវតក/កសចស, ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៨, កថាខណ្ឌ ៦។ រដ្ឋអាជ្ញា តទល់នឹង *Galić'*, សំណុំរឿង IT-98-29, "សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី សុំធ្វើការពិចារណាឡើងវិញ" ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៤ ("សេចក្តីសម្រេចលើការពិចារណាឡើងវិញ របស់ *Galic*"), សេចក្តីរៀបរាប់លើកទី ៩។

បណ្ដាលឲ្យមានភាពអយុត្តិធម៌”[8]។

5. នៅពេលសេចក្ដីសម្រេចដែលរងការជំទាស់ គឺជាអំណាចឆន្ទានុសិទ្ធិជាធម្មជាតិ នោះកត្តានានាដែលពាក់ព័ន្ធជាមួយការកំណត់ថា តើមានកំហុសដែលអាចមើលឃើញនៅក្នុងសេចក្ដីសម្រេចនេះ រួមទាំង *នៅក្នុងបញ្ហាដ៏ទៃទៀត* ថា តើសេចក្ដីសម្រេច “មិនយុត្តិធម៌ ឬមិនសមហេតុផលដែលបង្កើតជាការរំលោភអំណាចឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះដែរ ឬយ៉ាងណា”[9]។ ការពិចារណាត្រូវតែបានផ្ដល់ជូនផងដែរថា តើអង្គជំនុំជម្រះ នៅក្នុងការធ្វើសេចក្ដីសម្រេចតាមឆន្ទានុសិទ្ធិរបស់ខ្លួន “បានថ្លឹងថ្លែងការពិចារណាមិនចាំបាច់ ឬ មិនពាក់ព័ន្ធ ឬ ខកខានមិនបានផ្ដល់ទម្ងន់ ឬ ផ្ដល់ទម្ងន់គ្រប់គ្រាន់ទៅនឹងការពិចារណាដែលពាក់ព័ន្ធ”[10]។

## គ. ការរៀបចំសវនាការ

6. **វិធាន៨៥(១) នៃវិធានផ្ទៃក្នុងចែងនៅក្នុងផ្នែកពាក់ព័ន្ធថា:**

> ប្រធានអង្គជំនុំជម្រះសាលាដំបូងត្រូវដឹកនាំកិច្ចដំណើរការនិតិវិធី និង [...] <u>ត្រូវធានាដល់ការអនុវត្តសិទ្ធិការពារខ្លួនឲ្យប្រព្រឹត្តទៅបានដោយសេរី</u> ។ ដោយមានការពិគ្រោះយោបល់ជាមួយចៅក្រមផ្សេងទៀត ប្រធានសវនាការអាចបដិសេធនូវរាល់នីតិវិធីដែលនាំឲ្យមានការពន្យារពេលដល់ការជំនុំជម្រះ <u>និងដែលមិនអាចនាំទៅដល់ការស្វែងរកពិត</u> (បញ្ជាក់បន្ថែម)។

7. **វិធាន ៩១(៣) ចែងថា:**

> សហព្រះរាជអាជ្ញា ភាគីទាំងអស់ និង មេធាវីអាចជំទាស់ទៅនឹងការស្ដាប់ចម្លើយសាក្សីដែលកំពុងដំណើរការ ប្រសិនបើខ្លួនយល់ថា ចម្លើយរបស់សាក្សីនោះ<u>មិនសម្ដែងឲ្យឃើញការពិត</u> ។ នៅក្នុងករណីនេះប្រធានអង្គជំនុំជម្រះសាលាដំបូងគម្រូវសម្រេចថា តើត្រូវស្ដាប់ ឬមិនស្ដាប់ចម្លើយសាក្សីនេះ ។ (បញ្ជាក់បន្ថែម)។

---

[8] ឯកសារ **D164/4/9**, “សេចក្ដីសម្រេចលើសំណើសុំធ្វើការពិចារណាឡើងវិញ លើសេចក្ដីសម្រេចស្ដីពីសវនាការផ្ទាល់មាត់ លើបណ្ដឹងឧទ្ធរណ៍ អបជ ២៤ និង អបជ ២៥”, ថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩, កថាខណ្ឌ ១២។ ឯកសារ **C22/I/68**, “សេចក្ដីសម្រេចលើសំណើសុំពិចារណាឡើងវិញ អំពីសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការឆ្លើយតបចំពោះអង្គបុរេជំនុំជម្រះដោយផ្ទាល់”, ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨, កថាខណ្ឌ ២៥។ សេចក្ដីសម្រេចលើការពិចារណាឡើងវិញរបស់ *Galic*, សេចក្ដីរៀបរាប់លើកទី ៨។

[9] រដ្ឋអាជ្ញា តទល់និង *Lukić & Lukić*, សំណុំរឿង IT-98-32/1-A, “សេចក្ដីសម្រេច *Lukić & Lukić* ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១២ នៅកថាខណ្ឌ ១៧។

[10] ដូចខាងលើ ។

**សំណើរបស់ នួន ជា សុំកោះហៅ ប្រាក់ ខន សាក្សីថ្មី**

8. វិធានការសម្រាប់រៀបចំសវនាការដែលបង្កើតឡើងដោយអង្គជំនុំជម្រះសាលាដំបូង ត្រូវតែសមស្របជាមួយគោលការណ៍ជាសារវន្តរបស់តុលាការនេះ ដែលរួមបញ្ចូល*ក្នុងចំណោមបញ្ហាផ្សេងទៀត* គោលការណ៍ដែលមានចែងនៅក្នុងវិធាន២១(១)(ក) ដែលចែងថា:

> ដំណើរការនៅចំពោះមុខ អវតក ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាឲ្យបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគី ។ [...]

វិធានការក៏ត្រូវតែសមស្របជាមួយគោលការណ៍ដែលមានចែងនៅក្នុងមាត្រា៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("ច្បាប់ អវតក"):

> អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវប្រព្រឹត្តទៅឲ្យបានត្រឹមត្រូវ និងឆាប់រហ័សទៅតាមនីតិវិធីជាធរមាន ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនជាប់ចោទ និងមានការការពារឲ្យបានត្រឹមត្រូវចំពោះជនរងគ្រោះ និងសាក្សី ។
>
> [...]
>
> អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនសមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវនឹងដំណើរការសមស្របនៃច្បាប់ដូចដែលមានចែងនៅក្នុងមាត្រា១៤ និង១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិនយោបាយ និងពលរដ្ឋ។

9. មាត្រា១៤ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និង នយោបាយ ចែងថា:

> ៣. នៅក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយ ប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរិមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ ដូចខាងក្រោម:
>
> [...]
>
> ខ. ត្រូវមានពេលវេលា និង សម្ភារៈគ្រប់គ្រាន់សម្រាប់រៀបចំការពារខ្លួន និងឆ្លើយឆ្លងជាមួយ មេធាវីដែលជ្រើសរើសដោយខ្លួនឯង ។
>
> គ. ត្រូវបានជំនុំជម្រះដោយឥតពន្យារពេលយូរហួស ។
>
> [...]
>
> ង. ត្រូវសួរចម្លើយ ឬ សុំឲ្យសួរចម្លើយទៅលើសាក្សីដោះបន្ទុក និងសុំឲ្យសាក្សីដោះបន្ទុកចូលខ្លួន ដើម្បីសួរ

ចម្លើយក្នុងនាមខ្លួន ក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុកដែរ ។ [...]

## IV. អំណះអំណាង

### ក. លក្ខខណ្ឌសម្រាប់ការកោះហៅសាក្សីសារជាថ្មី ត្រូវបានបំពេញនៅក្នុងករណីប្រាក់ ខន

### *(i) ភស្តុតាងរំពឹងទុក នាំទៅដល់ការសម្តែងឲ្យឃើញការពិត និងមិនមែនជាភស្តុតាងត្រួត*

10. ក្រុមមេធាវីការពារក្តីមានបំណងចំរាញ់យកភស្តុតាងពី ប្រាក់ ខន លើវិធានបទខាងក្រោមដែលពាក់ព័ន្ធ និងនាំទៅដល់ការសម្តែងឲ្យឃើញការពិតៈ ការបូមយកឈាម[11] ការរំលោភផ្លូវភេទ[12] ការសម្លាប់កុមារវៀតណាម[13] របាយការណ៍ និង ចំណាររបស់អ្នកសួរចម្លើយ[14] កាលៈទេសៈលំអិត និងជាក់លាក់នៃការសួរចម្លើយអ្នកជាប់ឃុំបីនាក់ដែលសួរចម្លើយដោយប្រាក់ ខន[15] និងចលនា "ខ្មែររំដោះ" "ខ្មែរស" និង "ខ្មែរសេរី"[16] ។

11. ភាពពាក់ព័ន្ធ និងសារៈសំខាន់របស់ប្រធានបទភាគច្រើន គឺសាមញ្ញ ដូចដែលបានចែងខាងលើតាមរយៈការយោងចំពោះដីកាដំណោះស្រាយ ។ បន្ថែមពីលើនេះក្រុមមេធាវីការពារក្តីធ្វើការបញ្ជាក់ដូចខាងក្រោម ។

12. ជាដំបូង ការយល់ឲ្យច្បាស់នៃប្រព័ន្ធរាយការណ៍ និង ចំណាររបស់អ្នកសួរចម្លើយ អាចជួយអង្គជំនុំជម្រះនៅក្នុងការវាយតំលៃការដឹងរបស់ថ្នាក់លើអំពីឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ដូចជាការធ្វើទារុណកម្ម និងការប្រព្រឹត្ត ដោយមិនត្រឹមត្រូវនៅមន្ទីរសន្តិសុខស២១ ប្រសិនបើមាន ។

13. ទីពីកាលៈទេសៈលំអិតនៃការសួរចម្លើយជាក់លាក់ នឹងជួយអង្គជំនុំជម្រះនៅក្នុងការសម្រេចថា តើ

---

[11] សូមមើលឧទាហរណ៍ឯកសារ **D427** "ដីកាដំណោះស្រាយ" ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ("ដីកាដំណោះស្រាយ") នៅកថាខណ្ឌ ៤៧៣-៤៧៤ ។

[12] សូមមើលឧទាហរណ៍ឯកសារ **D427** ដីកាដំណោះស្រាយ នៅកថាខណ្ឌ ៤៥៩ ។

[13] សូមមើលឧទាហរណ៍ឯកសារ **D427** ដីកាដំណោះស្រាយ នៅកថាខណ្ឌ ៤៣៣, ៤៧១ ។

[14] សូមមើលឧទាហរណ៍ឯកសារ **D427** ដីកាដំណោះស្រាយ នៅកថាខណ្ឌ ៤៥៦ ។

[15] សូមមើលឧទាហរណ៍ឯកសារ **D427** ដីកាដំណោះស្រាយ នៅកថាខណ្ឌ ៤៤៨-៤៥៦ ។

[16] សូមមើលឧទាហរណ៍ឯកសារ **D427** ដីកាដំណោះស្រាយ នៅកថាខណ្ឌ ៤៥៥ ។

ការធ្វើទារុណកម្ម ឬការប្រព្រឹត្តដោយមិនត្រឹមត្រូវ បានកើតឡើងនៅក្នុងឧប្បត្តិហេតុទាំងនេះ ។ ផ្ទុយពីការថ្លែងច្របូកច្របល់ ឬ ការថ្លែងទូទៅអំពីថា តើ "ការធ្វើទារុណកម្ម" បានកើតមាននៅក្នុងមន្ទីរស២១ ភស្តុតាងដែលលំអិត និងជាក់លាក់ផ្តល់ឱកាសឲ្យអង្គជំនុំជម្រះសាលាដំបូងវាយតម្លៃភាពពិតប្រាកដនូវកម្រិតធ្ងន់ធ្ងរនៃការប្រព្រឹត្តមិនត្រឹមត្រូវ ដោយពិចារណា*កាលៈទេសៈទាំងអស់* រួមទាំងលក្ខណៈពិសេសរបស់ជនរងគ្រោះ ដូចជាអាយុ ភេទ និងស្ថានភាពសុខភាព[17]។ ម្យ៉ាងវិញទៀតការសួរដេញដោលសាក្សីទាក់ទងនឹងព័ត៌មានលំអិតពីកាលៈទេសៈនៃការសួរចម្លើយជាក់លាក់ អាចច្រានចោលសច្ចធារណ៍នៃហានិភ័យពិតមួយដែលថា ចម្លើយរបស់ជនរងគ្រោះត្រូវបានទាញយកតាមរយៈទារុណកម្មនៅក្នុងករណីជាក់លាក់នេះ[18]។ ទាំងអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលបានទទួលស្គាល់ថា ភាគីដែលស្នើសុំឲ្យប្រើប្រាស់ជាភស្តុតាងនូវចម្លើយសារភាពនេះ អាចណែនាំភស្តុតាងដើម្បីជំទាស់ទៅនឹងសច្ចាធារណ៍នៃហានិភ័យពិត[19] ។

14. ទីបីភស្តុតាងទាក់ទងនឹងចលនា "ខ្មែររំដោះ" "ខ្មែរស" និង "ខ្មែរសេរី" គឺពាក់ព័ន្ធជាទូទៅនឹងករណីរបស់ក្រុមមេធាវីការពារក្តី ដោយសារមានក្រុមប្រឆាំងនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ("ប.ក.ក") ក្នុងអំឡុងពេលយុត្តាធិការពេលវេលា (material time) ហើយថាក្រុមប្រឆាំងមួយចំនួនបានប៉ុនប៉ងផ្តួលរំលំកម្ពុជាប្រជាធិបតេយ្យ ដែលជារដ្ឋាភិបាលស្របច្បាប់និងមានការទទួលស្គាល់[20]។ ភស្តុ

---

[17] សូមមើលឧទាហរណ៍សំណុំរឿង *El-Masri* តទល់សាធារណៈម៉ាសេដូណៀនៃអតីតយូហ្គោស្លាវី , ECtHR, App. No. 39630/09, សេចក្តីសម្រេចថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១២ នៅកថាខណ្ឌ៩៥៥។

[18] ទាំងអង្គជំនុំជម្រះសាលាដំបូង និង អង្គជំនុំតុលាការកំពូល បានយល់ឃើញថា មានសច្ចាធារណ៍ដែលអាចជំទាស់បាននៃហានិភ័យពិតមួយ ដែលថាចម្លើយសារភាពនៅមន្ទីរសន្តិសុខស២១ បានមកដោយដោយការធ្វើទារុណកម្ម ដូច្នេះមិនត្រូវសំអាងជាភស្តុតាងឡើយ អនុលោមតាមមាត្រា១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬ បន្ទាបបន្ថោក ។ ឯកសារ **E350/8** "សេចក្តីសម្រេចលើភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម" ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៦ ("សេចក្តីសម្រេចរបស់អង្គជំនុំចម្រះសាលាដំបូង") នៅកថាខណ្ឌ៧៩ ។ ឯកសារ **F26/12** "សេចក្តីសម្រេចលើសេចក្តីជំទាស់ទៅនឹងបញ្ជីឯកសារសំអាងហេតុពេញលេញ" ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ("សេចក្តីសម្រេចរបស់អង្គជំនុំជម្រះរបស់តុលាការកំពូល") នៅកថាខណ្ឌ៥៦-៥៨ ។

[19] **E350/8** សេចក្តីសម្រេចរបស់អង្គជំនុំចម្រះសាលាដំបូង នៅកថាខណ្ឌ៣៦ និង ៧៩។ **F26/12** សេចក្តីសម្រេចរបស់អង្គជំនុំជម្រះរបស់តុលាការកំពូលនៅកថាខណ្ឌ ៥៨ ។

[20] ក្រុមមេធាវីការពារក្តីនឹងដាក់សារណាលំអិតជាលាយលក្ខណ៍អក្សរលើករណីរបស់ខ្លួនទាក់ទងនឹងក្រុមប្រឆាំង ដូចដែលបានស្នើសុំដោយអង្គជំនុំជម្រះសាលាដំបូង ។ សូមមើលឯកសារ **E395/1**, "សំណើសុំដាក់សារណាទាក់ទងនឹងក្រុមប្រឆាំងជាក់លាក់នៅក្នុងមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ" ថ្ងៃទី១១ ខែ ឧសភា ឆ្នាំ២០១៦ ។

តាងនៅក្នុងចំណោមនោះអាចពាក់ព័ន្ធទៅនឹងការដឹងរបស់ នួន ជា អំពីបទឧក្រិដ្ឋជាក់លាក់នៅក្នុងតំបន់ដែលគ្រប់គ្រងដោយក្រុមប្រឆាំង និងការគ្រប់គ្រងរបស់ជនជាប់ចោទលើអ្នកប្រព្រឹត្ត ដែលស្ថិតនៅក្រោមការត្រួតត្រារបស់ក្រុមប្រឆាំង។ ម្យ៉ាងទៀតភស្តុតាងបែបនេះអាចពាក់ព័ន្ធទៅនឹងការចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការដាក់ក្នុងមន្ទីរឃុំឃាំង[21] ដែលនាំឲ្យមានការបដិសេធសេរីភាពតាមអំពើចិត្ត[22]។ ការធ្វើតាមអំពើចិត្តក្នុងករណីនេះ យោង*ក្នុងចំណោមបញ្ហាដ៏ដទៃទៀត* ទៅលើកង្វះមូលដ្ឋានផ្លូវច្បាប់[23]។ ដូច្នោះហើយភស្តុតាងទាំងឡាយណាដែលសន្និដ្ឋានពីអត្ថិភាពនៃមូលដ្ឋានច្បាប់ចំពោះការដកហូតសេរីភាព ដូចជាការសង្ស័យថា ជនរងគ្រោះបានពាក់ព័ន្ធអំពើបទឧក្រិដ្ឋក្បត់ជាតិ គឺមិនពាក់ព័ន្ធនឹងករណីនេះទេ ។

15. ភស្តុតាងដែលរំពឹងទុក គឺមិនត្រឹមតែពាក់ព័ន្ធ និង សំខាន់ទេ តែក៏មិនមែនជាភស្តុតាងត្រួតគ្នាដែរ ។ តាមពិតដែលនឹងបង្ហាញខាងក្រោម ភស្តុតាងដែលរំពឹងទុកភាគច្រើនមិនអាចទទួលបានពីប្រភពផ្សេងទៀតក្រៅពី ប្រាក់ ខន ឡើយ។ ទីមួយ ប្រាក់ ខន គឺជាសាក្សីផ្ទាល់ភ្នែកតែម្នាក់គត់នៃការប្ញូមឈាម និងការសម្លាប់កុមារវៀតណាមនៅស២១ ។ ទីពី ប្រាក់ ខន គឺជាអ្នកសួរចម្លើយតែម្នាក់គត់ដែលបានសួរចម្លើយបុគ្គលបីនាក់ ដែលរៀបរាប់ពីខាងលើ[24]។ ទីបី ប្រាក់ ខន គឺជាសាក្សីម្នាក់ក្នុងចំណោមសាក្សីពីរនាក់-ម្នាក់ទៀតគឺ ឡាច មាន ដែលហាក់ដូចជាជំទាស់ទៅនឹងព័ត៌មានទាក់ទងនឹងការរំលោភផ្លូវភេទតាមការសន្មត ដែលជាប់ពាក់ព័ន្ធជាមួយអ្នកសួរចម្លើយម្នាក់ឈ្មោះ ទូច[25]។ ទីបួន ប្រាក់ ខន គឺជាអតីតអ្នកសួរចម្លើយតែម្នាក់គត់ ក្នុងចំណោមអតីតអ្នកសួរចម្លើយពីរនាក់ ដែលគ្រោងចូលខ្លួនផ្តល់សក្ខីកម្មទាក់ទងទៅនឹងស២១ ហើយគាត់ជាអ្នកសួរចម្លើយយូរជាងសាក្សី ឡាច មាន ហើយដូច្នេះគាត់អាចផ្តល់ភស្តុតាងទាក់ទងទងនឹងស្ថានភាពដែលគ្រប់ដណ្តប់ពេលវេលាយូរ ដែលសាក្សី ឡាច មាន មិនមានការដឹងដោយផ្ទាល់ ។ ទីប្រាំ ប្រាក់ ខន បានប្រាប់អ្នកស៊ើប

---

[21] ឯកសារ **D427** ដីកាដំណោះស្រាយ នៅកថាខណ្ឌ ១៤០២-១៤០៧ ។

[22] សូមមើលឧទាហរណ៍ករណីរដ្ឋអាជ្ញា តទល់ *Krnojelac*, "សាលក្រម" សំណុំរឿងលេខ IT-97-25-T ថ្ងៃទី១៥ ខែមីនា ឆ្នាំ ២០០២ ("សាលក្រមអង្គជំនុំជម្រះសាលាដំបូង *Krnojelac*") នៅកថាខណ្ឌ៥៨ ។

[23] សាលក្រម *Krnojelac* នៅកថាខណ្ឌ១១៥ ។ ដីកាដំណោះស្រាយចោទថា "ប្រជាជនរាប់ពាន់នាក់ដែលត្រូវបានឃុំខ្លួននៅក្នុងមន្ទីរសន្តិសុខ គឺធ្វើឡើងដោយចេតនា និងតាមអំពើចិត្តដោយគ្មានមូលដ្ឋានច្បាប់ណាមួយឡើយ" ។ សូមមើល **D427** ដីកាដំណោះស្រាយ នៅកថាខណ្ឌ១៤០៤ (បញ្ជាក់បន្ថែម)។

[24] សូមមើលកថាខណ្ឌ១០ខាងលើ នៅជើងទំព័រ១៥ ។

[25] **D427** ដីកាដំណោះស្រាយ នៅកថាខណ្ឌ៤៥៩ ជើងទំព័រ ១៩៩៨ ។

អង្កេត អវតក ថា គាត់បានចូលរួមចលនា “ខ្មែររំដោះ” នៅឆ្នាំ១៩៧៣[26]។ មានភស្តុតាងបញ្ជាក់ថា ចលនា “ខ្មែររំដោះ” និង “ខ្មែរសេរី” ជាប់ទាក់ទងគ្នានៅដើមឆ្នាំ១៩៧០[27] ហើយថាសាខារបស់ “ខ្មែររំដោះ” ដែលគាំទ្រដោយវៀតកុង បានប៉ះទង្គិចជាមួយទាហានខ្មែរក្រហមចាប់តាំងពីឆ្នាំ ១៩៧៣[28]។

16. ជាសង្ខេបភស្តុតាងដែលក្រុមមេធាវីការពារក្តីចង់ចំរាញ់យកពី ប្រាក់ ខន គឺពាក់ព័ន្ធ និងសំខាន់ចំពោះការបញ្ជាក់ឲ្យឃើញការពិត និងមិនមែនជាភស្តុតាងត្រួតគ្នា ។

*(ii)* ***ការខកខានមិនបានចំរាញ់យកភស្តុតាងដែលរំពឹងទុកក្នុងអំឡុងពេលការផ្តល់សក្ខីកម្មដំបូង គឺសមហេតុសមផល***

17. ដូចបានរៀបរាប់ពីខាងលើ[29] ក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់ ប្រាក់ ខន ក្រុមមេធាវីការពារក្តី បានបំពេញតួនាទីប្រកបដោយវិរយភាព និងបានធ្វើសំណើសមហេតុផលមួយ សុំពេលវេលាបន្ថែម ដើម្បីសួរដេញដោល ប្រាក់ ខន នៅពេលក្រុមមេធាវីការពារក្តីយល់ច្បាស់ថាពេលវេលាដែលបានបែងចែក គឺមិនគ្រប់គ្រាន់សម្រាប់ការសួរដេញដោលទូលំទូលាយ និងពេញលេញនោះ។ នៅក្នុងការស្នើសុំនេះ ក្រុមមេធាវីការពារក្តីបានចង្អុលបង្ហាញនូវប្រធានបទមួយចំនួនដែលខ្លួនចង់បិពិភាក្សាជាមួយ ប្រាក់ ខន[30]។ តែសំណើនេះត្រូវបានបដិសេធដោយភាន់ច្រឡំពីអង្គជនុំជម្រះសាលាដំបូង ដូចដែលនឹងបង្ហាញលំអិតនៅខាងក្រោម ទាក់ទងនឹងសំណើសុំពិចារណាឡើងវិញ ។ ដូច្នោះហើយ ការខកខានមិនបានចំរាញ់យកភស្តុតាងដែលរំពឹងទុកនៅក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មលើកដំបូងរបស់ ប្រាក់ ខន គឺមិនមែនជាកំហុសរបស់ក្រុមមេធាវីការពារក្តីឡើយ ។

18. ផ្អែកលើហេតុផលខាងលើក្រុមមេធាវីការពារក្តីយល់ឃើញថា លក្ខខណ្ឌកោះហៅ ប្រាក់ ខន សារ

---

[26] **E3/5156** កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយប្រាក់ ខន” ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ ២០០៧ EN 00161570-71

[27] **E3/1593**, B. Kiernan, *The Pol Pot Regime: Race, Power and Genocide in Cambodia under the Khmer Rouge, 1975-79*, នៅទំព័រ ៦៨, EN 01150031

[28] **E3/2376**, N. Chanda, *Brother Enemy*, នៅទំព័រ, 66, 72, EN 00192251, 00192257

[29] សូមមើលកថាខណ្ឌ២ ខាងលើ ។

[30] ប្រតិចារិតថ្ងៃសវនាការទី២ ខែឧសភា ឆ្នាំ២០១៦ (ពង្រាងប្រតិចារិត ប្រាក់ ខន) នៅទំព័រ៤៣ បន្ទាត់ ១៣-២២ ។

ជាថ្មី ត្រូវបានបំពេញ ។

## ខ. កំហុសដែលអាចមើលឃើញនៅក្នុងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបដិសេធ សំណើរបស់ក្រុមមេធាវីការពារក្ដី សុំពេលវេលាបន្ថែមដើម្បីសួរដេញដោល ប្រាក់ ខន ផ្ដល់ហេតុផលឱ្យពិចារណាឡើងវិញ

19. នៅក្នុងការបដិសេធលើសំណើរបស់ក្រុមមេធាវីការពារក្ដីសុំពេលវេលាបន្ថែម អង្គជំនុំជម្រះសាលាដំបូងមិនបានបញ្ជាក់ពីមូលហេតុនៅខាងក្រោយសេចក្ដីសម្រេចរបស់ខ្លួនទេ[31]។ ប៉ុន្តែក្នុងអំឡុងពេលការផ្ដល់សក្ខីកម្មរបស់ ប្រាក់ ខន ប្រធានអង្គជំនុំជម្រះសាលាដំបូងបានចង្អុលបង្ហាញការពិចារណាមួយចំនួនដែលអង្គជំនុំជម្រះសាលាដំបូងអាចបានធ្វើនៅពេលចេញសម្រេចរបស់ខ្លួនៈ

> អនុញ្ញាតឱ្យខ្ញុំបំភ្លឺថា អង្គជំនុំជម្រះជាធម្មតាធ្វើឱ្យមានតុល្យភាពពេលវេលាដែលបានបែងចែកឱ្យភាគី ហើយសម្រាប់ភាគីដែលតាំងសំណួរ ដែលមិនពាក់ព័ន្ធ និងមិនជួយបញ្ជាក់នូវការពិត ដូច្នេះអង្គជំនុំជម្រះអាចបញ្ឈប់ការតាំងសំណួរ [...]
>
> ពេលវេលាត្រូវតែបែងចែកស្មើគ្នាគ្រប់ភាគីទាំងអស់ ។ ជាធម្មតាភាគីមួយមិនអាចមាននាទីបន្ថែមច្រើនជាងភាគីផ្សេងឡើយ[32] ។

20. តាមពិតអង្គជំនុំជម្រះមានអំណាចឆន្ទានុសិទ្ធិនៅក្នុងការកំណត់វិធានការទាក់ទងនឹងការរៀបចំសវនាការ ។ តែដូចដែលបានរៀបរាប់ខាងលើ[33] នៅក្នុងការអនុវត្តឆន្ទានុសិទ្ធិនៅក្នុងចំណុចនេះ អង្គជំនុំជម្រះសាលាដំបូង ត្រូវធានាការជំនុំជម្រះដោយយុត្តិធម៌ ដោយគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនជាប់ចោទនិងការអនុវត្តដោយសេរីនូវសិទ្ធិការពារ[34]។ ដោយគិតគូរការពិចារណាទាំងនេះ ប្រធានអង្គជនុំជម្រះសាលាដំបូង ដោយមានការពិគ្រោះយោបល់ជាមួយចៅក្រមផ្សេងទៀត អាចបដិសេធនូវរាល់នីតិវិធីដែលនាំឱ្យមានការពន្យារពេលដល់ការជំនុំជម្រះ និងដែលមិនអាចនាំទៅ

---

[31] ប្រតិចារិតថ្ងៃសវនាការទី២ ខែឧសភា ឆ្នាំ២០១៦ (ពង្រាងប្រតិចារិត ប្រាក់ ខន) នៅទំព័រ៤៤ បន្ទាត់ ៦-១៣ ។

[32] ប្រតិចារិតថ្ងៃសវនាការទី២ ខែឧសភា ឆ្នាំ២០១៦ (ពង្រាងប្រតិចារិត ប្រាក់ ខន) នៅទំព័រ៣៦ បន្ទាត់ ១១-១៤ ។ ទំព័រ១០៤ បន្ទាត់១៩-២១ ។

[33] សូមមើលកថាខណ្ឌ៦-៩ ខាងលើ ។

[34] មាត្រា ៣៣ថ្មី នៃច្បាប់បង្កើត អវតក ។ វិធាន២១(១)(ក) និង វិធាន៨៥(១) នៃវិធានផ្ទៃក្នុង ។

ដល់ការបញ្ជាក់ការពិត"[35] ។

21. ដូចដែលបានបង្ហាញ[36] ភស្តុតាងដែលក្រុមមេធាវីការពារក្ដីមានបំណងចំរាញ់យកពី ប្រាក់ ខន គឺសំខាន់សម្រាប់ការបញ្ជាក់ការពិត និងមិនមែនជាភស្តុតាងត្រួតគ្នា ហើយពេលវេលាបន្ថែមគឺចាំបាច់នៅក្នុងការទទួលបានភស្តុតាងបែបនេះ ។ ដូច្នេះការសួរដេញដោល ប្រាក់ ខន ដោយក្រុមមេធាវីការពារក្ដី មិនបង្កើតឲ្យមានការពន្យារពេលដល់ការជំនុំជម្រះឡើយ ។

22. មួយវិញទៀតដូចដែលនឹងបង្ហាញលំអិត នៅក្នុងការអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីឈានដល់ការចេញសេចក្ដីសម្រេចដែលរងការជំទាស់នេះ អង្គជំនុំជម្រះសាលាដំបូងបានថ្លឹងថ្លែងការពិចារណាដែលមិនពាក់ព័ន្ធ ខណៈដែលខកខានមិនបានថ្លឹងថ្លែងឲ្យបានសមរម្យការពិចារណាដែលពាក់ព័ន្ធទៅវិញ[37] ។

### *(ii) តុល្យភាពរវាងការជំនុំជម្រះដោយយុត្តិធម៌ និង ការជំនុំជម្រះឆាប់រហ័ស*

23. ខណៈដែលភាពឆាប់រហ័ស គឺជាការពិចារណាដែលពាក់ព័ន្ធនៅក្នុងការរៀបចំសវនាការ តែវាមិនសំខាន់ជាងការជំនុំជម្រះដោយយុត្តិធម៌ទេ ។ ដូចដែលគណៈកម្មាធិការសិទ្ធិមនុស្សបានលើកឡើង:

> សិទ្ធិរបស់ជនជាប់ចោទម្នាក់ដើម្បីទទួលបានពេលវេលា និង មធ្យោបាយគ្រប់គ្រាន់សម្រាប់រៀបចំការពារក្ដីរបស់គាត់ គឺជាធាតុផ្សំសំខាន់មួយនៃការធានាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងជាលទ្ធផលនៃគោលការណ៍សមភាពនៃមធ្យោបាយនៃការតតាំងក្ដី[38] ។

24. នៅក្នុងករណី *Papadakis* តុលាការសិទ្ធិមនុស្សអឺរ៉ុប ("ECtHR") រកឃើញថាពេលវេលាគ្រប់គ្រាន់ដែលផ្ដល់ទៅឲ្យម្ចាស់បណ្ដឹង ដើម្បីសួរដេញដោលសាក្សីប្រឆាំងនឹងគាត់ "បានដាក់ម្ចាស់បណ្ដឹងនៅក្នុងជំហរមួយ ដែលគាត់ត្រូវបានបដិសេធនូវឱកាសពិតក្នុងការជំទាស់តវ៉ាភាពអាចទុក

---

[35] វិធាន៨៥(១) នៃវិធានផ្ទៃក្នុង បញ្ជាក់បន្ថែម ។ សូមមើលផងដែរ វិធាន៩១(៣)។

[36] សូមមើលកថាខណ្ឌ១០-១៨ ខាងលើ ។

[37] សូមមើលកថាខណ្ឌ៥ ខាងលើ ដោយបានយោងសាលក្រម *Lukić & Lukić* នៅកថាខណ្ឌ១៧ ។

[38] រឿងក្ដីរវាង *Little* តទល់. *Jamaica* Communication No. 283/1988, U.N. Doc. CCPR/C/43/D/283/1988 (1991), 1 Nov 1991, para. 8.3.

ចិត្តបាននៃភស្តុតាងប្រឆាំងនឹងគាត់[39] ។ នៅក្នុងគំនិតរបស់តុលាការ ECtHR ការព្រួយបារម្ភដែលថាការបន្ថែមពេលវេលានឹងពន្យារពេលដល់នីតិវិធី "មិនអាចធ្វើយុត្តិកម្មនៃដាក់កម្រិតធ្ងន់ធ្ងរលើសិទ្ធិការពាររបស់ម្ចាស់បណ្តឹងឡើយ" ពិព្រោះ"សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គឺជាធាតុផ្សំដ៏សំខាន់នៅក្នុងសង្គមប្រជាធិបតេយ្យ ដែលមិនអាចលះបង់ដោយភាពឆាប់រហ័សឡើយ"[40]។ ដូច្នេះតុលាការ ECtHR យល់ឃើញថា នៅក្នុងកាលៈទេសៈនៃរឿងក្តីនោះ "ឧបសគ្គដែលធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តសិទ្ធិការពាររបស់គាត់ គឺមិនអាចផ្សះផ្សារបានជាមួយការធានាការជំនុំជម្រះដោយយុត្តិធម៌បានឡើយ"[41] ។

25. អង្គជំនុំជម្រះតុលាការកំពូលបានប្រកាន់ជំហរដូចគ្នាទាក់ទងនឹងតុល្យភាពរវាងប្រសិទ្ធិភាព និងតម្លៃជាសារវន្តរបស់ច្បាប់។ ទាក់ទងទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដើម្បីបំបែកសំណុំរឿង០០២ អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញ:

> អង្គជំនុំជ្រះតុលាការកំពូលចាត់ទុកថា ការរំពឹងទុករបស់អង្គជំនុំជម្រះសាលាដំបូងលើបញ្ហាហិរញ្ញវត្ថុ ថាជាការពុំជាប់ពាក់ព័ន្ធ និងពុំសមស្របនៅក្នុងការធ្វើសេចក្តីសម្រេចបច្ចុប្បន្ន។ ដោយហេតុថាចៅក្រម នៅគ្រប់ពេលទាំងអស់ ជាក់ច្បាស់ណាស់ ត្រូវមានកាតព្វកិច្ចពិចារណាលើប្រសិទ្ធិភាពនៃកិច្ចដំណើរការនីតិវិធី ដូច្នេះចៅក្រមជានិច្ចជាកាលត្រូវអនុវត្តទៅតាមវិសាលភាពនៃច្បាប់ ដែលជាគោលការណ៍ដែលមានលក្ខណៈសំខាន់ជាងការសន្សំសំចៃផ្នែកថវិកា[42]។

26. ដូច្នេះក្រុមមេធាវីការពារក្តីយល់ឃើញថា នៅក្នុងការឲ្យតម្លៃភាពឆាប់រហ័ស (expediency) សំខាន់ជាងយុត្តិធម៌ (fairness) អង្គជំនុំជម្រះសាលាដំបូងមិនបានថ្លឹងថ្លែងឲ្យបានសមរម្យការពិចារណាដែលពាក់ព័ន្ធនិមួយៗ ហើយហេតុនេះបានប្រព្រឹត្តនូវកំហុសនៅក្នុងសេចក្តីសម្រេចតាមអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន មិនអនុញ្ញាតនូវពេលវេលាបន្ថែមឲ្យក្រុមមេធាវីការពារក្តី ។

---

[39] រឿងក្តី *Papadakis* តទល់អតីតសាធារណៈ *Macedonia* នៃអតីតយូហ្គោស្លាវី "សេចក្តីសម្រេច" ECtHR បណ្តឹងលេខ 50254/07 ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៣ នៅកថាខណ្ឌ៩៤។

[40] រឿងក្តី *Papadakis* តទល់អតីតសាធារណៈ *Macedonia* នៅកថាខណ្ឌ៩៤ ។

[41] រឿងក្តី *Papadakis* តទល់អតីតសាធារណៈ *Macedonia* នៅកថាខណ្ឌ៩៥ ។

[42] **E284/4/8**, សេចក្តីសម្រេចលើបណ្តឹងសារទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២ ថ្ងៃទី២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ នៅកថាខណ្ឌ៧៥ ។

## *(ii) ការគ្រប់គ្រងពេលវេលា និង សមភាពនៃមធ្យោបាយនៃការតតាំងក្តី*

27. សមភាពនៃមធ្យោបាយនៃការតតាំងក្តី គឺជាការពិចារណាដែលពាក់ព័ន្ធនៅក្នុងការរៀបចំសវនាការ ប៉ុន្តែដូចដែលបានលើកឡើងដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់ ICTY នៅក្នុងសំណុំរឿង *Orić* សមភាពនៃមធ្យោបាយនៃការតតាំងក្តី មិនតម្រូវនូវចំនួនពេលវេលាដូចគ្នាសម្រាប់ទាំងព្រះរាជអាជ្ញា និងមេធាវីការពារក្តីឡើយ ។ តាមពិតវាគឺ "ជាគោលការណ៍សមាមាត្រជាមូលដ្ឋាន មិនមែនជាគោលការណ៍តឹងរ៉ឹងនៃភាពស្មើគ្នាបែបគណិតវិទ្យានោះទេ ដែលជាទូទៅគ្រប់គ្រងលើទំនាក់ទំនងរវាងពេលវេលា និង សាក្សី ដែលបានបែងចែកឱ្យភាគីទាំងពីរ"[43] ។ នៅក្នុងការសម្រេចសមាមាត្រជាមូលដ្ឋាន (basic proportionality) អង្គជំនុំជម្រះគប្បីពិចារណា *ក្នុងចំណោមបញ្ហាផ្សេងទៀត* មុខងារទូទៅ ព្រមទាំងយុទ្ធសាស្ត្រជាក់លាក់របស់ព្រះរាជអាជ្ញា និង ការការពារក្តីនៅក្នុងករណីពិសេស[44]។

28. នៅក្នុងសំណុំរឿងនេះ សហព្រះរាជអាជ្ញារងអន្តរជាតិជ្រើសរើសពឹងផ្អែកភស្តុតាង និងការពិភាក្សានៅក្នុងសំណុំរឿង០០១ នៅពេលស្តាប់សក្ខីកម្មរបស់ ប្រាក់ ខន នៅក្នុងសំណុំរឿង០០២/០២[45]។ ផ្ទុយមកវិញ យុទ្ធសាស្ត្ររបស់មេធាវីការពារក្តីគឺសួរដេញដោល ប្រាក់ ខន ឱ្យបានលម្អិតទៅលើទិដ្ឋភាពទាំងអស់ និងចំរាញ់យកភស្តុតាងដើម្បីគាំទ្រដល់ការការពារក្តីរបស់ខ្លួន ។ ការពិចារណាយុទ្ធសាស្ត្រជាក់លាក់ដែលជ្រើសរើសដោយភាគីទាំងពីរ ចំនួនពេលវេលាដូចគ្នា នឹងមិនបំពេញសមាមាត្រាជាមូលដ្ឋាន ដែលតម្រូវដោយគោលការណ៍សមភាពនៃមធ្យោបាយនៃការតតាំងក្តី។ ដូច្នេះក្រុមមេធាវីការពារក្តីយល់ឃើញថា ខ្លួនមានសិទ្ធិទទួលបានពេលវេលាច្រើនថែមទៀត នៅក្នុងករណីពិសេសនេះ ។

29.ម្យ៉ាងវិញទៀតដូចដែលបានកត់សម្គាល់យ៉ាងត្រឹមត្រូវដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY អំណាចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងកម្រិតពេលវេលាដែលបានចែងបែកឱ្យមេធាវីការពារក្តីជានិច្ចជាកាលត្រូវតែស្ថិតនៅក្រោមលក្ខខណ្ឌទូទៅដែលថា សិទ្ធិរបស់ជនជាប់ចោទត្រូវបានគោរព

---

[43] ព្រះរាជអាជ្ញា តទល់ *Orić* សេចក្តីបន្ទាន់បង្គំ (Interlocutory Decision) លើថិរវេលានៃករណីការពារក្តី សំណុំរឿង IT-03-68-AR73.2 ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៥ ("សេចក្តីសម្រេច *Orić* ") នៅកថាខណ្ឌ៧ ។

[44] សេចក្តីសម្រេច *Orić* នៅកថាខណ្ឌ៧ ។

[45] ប្រតិចារិតសវនាការថ្ងៃទី២៧ ខែ មេសា ឆ្នាំ២០១៦ (ពង្រាងប្រតិចារិត ប្រាក់ ខន) នៅទំព័រ៥៧ បន្ទាត់៩-១៦ ។

យ៉ាងពេញលេញ:

> ដូច្នេះចំពោះពេលវេលាដែលបានបែងចែកឲ្យព្រះរាជអាជ្ញា សំណួរថា តើពេលវេលាដែលបានផ្តល់ឲ្យជនជាប់ចោទ គឺសមាមាត្រាសមហេតុផលដែរ ឬយ៉ាងណា អង្គជំនុំជម្រះសាលាដំបូងក៏ត្រូវពិចារណាផងដែរថា តើចំនួនពេលវេលា គឺគ្រប់គ្រាន់ពិតប្រាកដដើម្បីអនុញ្ញាតឲ្យជនជាប់ចោទរៀបចំករណីរបស់គាត់នៅក្នុងលក្ខណៈសមស្របជាមួយសិទ្ធិរបស់គាត់ដែរ ឬយ៉ាងណា[46] ។

30. ដូច្នេះអនុលោមតាមអង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY សំណួរថាតើ "ការយកមកពិចារណាភាពស្មុគស្មាញរបស់បញ្ហាដែលសេសសល់" ចំនួនពេលវេលាដែលបានបែងចែកឲ្យមេធាវីការពារក្តីគឺ "សមាមាត្រសមហេតុផលទាំងពីរ" ទៅនឹងពេលវេលាដែលបានបែងចែកឲ្យព្រះរាជអាជ្ញា និងគ្រប់គ្រាន់ដើម្បីឲ្យជនជាប់ចោទទទួលបានឱកាសស្មើគ្នា ដើម្បីបង្ហាញករណីរបស់គាត់"[47]។

31. នៅក្នុងសំណុំរឿងនេះដូចដែលបានបង្ហាញពីខាងលើ[48] ការបន្ថែមពេលវេលា គឺចាំបាច់សម្រាប់ក្រុមមេធាវីការពារក្តីទទួលបាននូវឱកាសស្មើគ្នា ដើម្បីរៀបចំការពារក្តីឲ្យបានពេញលេញ និងមានប្រសិទ្ធិភាព ។

32. ផ្អែកខាងលើក្រុមមេធាវីការពារក្តីយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដែលអាចមើលឃើញនៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់នេះ ដោយបានថ្លឹងថ្លែងការពិចារណាដែលមិនពាក់ព័ន្ធ ដូចជាភាពស្មើគ្នាបែបគណិតវិទ្យានៃពេលវេលាដែលបានបែងចែក ខណៈដែលមិនបានថ្លឹងថ្លែងឲ្យបានគ្រប់គ្រាន់ពីសមាមាត្រា និង ភាពគ្រប់គ្រាន់ពិតប្រាកដនៃពេលវេលា ដែលមេធាវីការពារក្តីមានសិទ្ធិទទួល ។

### *(iii) ការប្រើប្រាស់ដោយក្រុមមេធាវីការពារក្តីនៃពេលវេលាដែលបានបែងចែកពីលើកមុន គឺស្របច្បាប់*

33. ក្រុមមេធាវីការពារក្តីកត់សម្គាល់ថា តម្រូវការពេលវេលាបន្ថែម គឺដោយសារពេលវេលាដែលបានបែងចែក មិនគ្រប់គ្រាន់ពិតប្រាកដ និងដោយសារចំនួនបញ្ហាដ៏ច្រើនដែលក្រុមមេធាវីការពារក្តីចង់ពិភាក្សាជាមួយ ប្រាក់ ខន ។ វាមិនដោយសារការប្រើប្រាស់មិនស្របច្បាប់នូវពេលវេលាដែលបាន

---

[46] សេចក្តីសម្រេច *Orić* នៅកថាខណ្ឌ៨ ។ (បញ្ជាក់បន្ថែម)

[47] សេចក្តីសម្រេច *Orić* នៅកថាខណ្ឌ៩។

[48] សូមមើលកថាខណ្ឌ១០-១៨ ខាងលើ ។

បែងចែកឲ្យក្រុមមេធាវីការពារក្តីឡើយ។ រាល់ប្រធានបទទាំងអស់ដែលលើកមកពិភាក្សាក្នុងអំឡុងពេលសួរដេញដោលរបស់ខ្លួនមកលើ ប្រាក់ ខន គឺពាក់ព័ន្ធ និងអាចជួយបញ្ជាក់ការពិត ។

34. សហព្រះរាជអាជ្ញារងអន្តរជាតិជំទាស់ថា ក្រុមមេធាវីការពារក្តីបានខ្ជះខ្ជាយពេលវេលាតាមរយៈការមិនយកចិត្តទុកដាក់ដោយចេតនានូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង មិនអនុញ្ញាតឲ្យលើកមកសំអាងខ្លឹមសារនៃចម្លើយសារភាពរបស់អ្នកទោសនៅស២១ ដោយសារមានហានីភ័យពិតដែលមិនអាចជំទាស់បានថា ចម្លើយសារណាទទួលបានពីទារុណកម្ម[49] ។ ផ្ទុយពីការជំទាស់នេះ ក្រុមមេធាវីការពារក្តី គោរពយ៉ាងប្រយ័ត្នប្រយែងតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងភស្តុតាងដែលជិតដាមដោយទារុណកម្ម នៅពេលសួរដេញដោល ប្រាក់ ខន[50]។ ពេលវេលាតែមួយគត់ដែលក្រុមមេធាវីការពារក្តីយោងដោយមិនច្បាស់ទៅលើខ្លឹមសាររបស់ចម្លើយសារភាពរបស់អ្នកទោសម្នាក់ គឺក្នុងអំឡុងពេលឆ្លងឆ្លើយជាមួយចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង នៅពេលក្រុមមេធាវីការពារក្តីស្វែងរកការពន្យល់ដល់អង្គជំនុំជម្រះពីចរិតនៃសំណួរដែលខ្លួនត្រូវសួរទៅកាន់ ប្រាក់ ខន[51] ។

35. សំណួរដែលក្រុមមេធាវីការពារក្តីសួរទៅ ប្រាក់ ខន គឺថា តើអ្នកទោសម្នាក់ឈ្មោះ ឆុន បានផ្តល់ព័ត៌មាននៅក្នុងចម្លើយភាពរបស់គាត់ "ដោយឯកឯង" គឺថា ដោយខ្លួនគាត់ ឬ ថាតើ ប្រាក់ ខន ដែលជាអ្នកសួរចម្លើយនៅស២១ ផ្តល់ព័ត៌មានទៅ ឆុន ដែរ ឬយ៉ាងណា[52]។ ដូចដែលចៅក្រម Fenz បានទទួលស្គាល់[53] សំណួរនេះ គឺស្របច្បាប់ទាំងស្រុង ។ សំណួរនេះទាក់ទងដោយផ្ទាល់ទៅនឹងការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ:

> "ការពិត" ដែលបាននិយាយនៅក្នុងចម្លើយសារភាព គឺត្រូវបានកំណត់ទុកជាមុនរួចទៅហើយ ព្រោះថាអ្នកសួរចម្លើយបានបង្ខំឲ្យអ្នកជាប់ឃុំផ្តល់នូវចម្លើយដែលបានកំណត់ទុកជាមុន ដោយទទួលបានការណែនាំពី ឌុ

---

[49] ប្រតិចារិតសវនាការថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៦ (ពង្រាងប្រតិចារិត ប្រាក់ ខន) នៅទំព័រ២៨ បន្ទាត់៣-៨ ។

[50] សូមមើលឧទាហរណ៍ប្រតិចារិតសវនាការថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ (ពង្រាងប្រតិចារិត ប្រាក់ ខន) នៅទំព័រ៣៧ បន្ទាត់ ១-៥, នៅទំព័រ៧១ បន្ទាត់២៤-២៥

[51] ប្រតិចារិតសវនាការថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ (ពង្រាងប្រតិចារិត ប្រាក់ ខន) នៅទំព័រ៨៥ បន្ទាត់១៧ ។

[52] ប្រតិចារិតសវនាការថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ (ពង្រាងប្រតិចារិត ប្រាក់ ខន) នៅទំព័រ៨៣ បន្ទាត់១៦-១៧, ទំព័រ៨៤ បន្ទាត់ ១០-១៤ ។

[53] ប្រតិចារិតសវនាការថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ (ពង្រាងប្រតិចារិត ប្រាក់ ខន) នៅទំព័រ៨៤ បន្ទាត់១៦-២២ ។

ច ឲ្យថាមានទំនាក់ទំនងជាមួយសេអ៊ុអា កាហ្សេបេ និង/ឬពួកវៀតណាម[54]។

36. ភស្តុតាងចំពោះប្រធានបទនេះ ក៏ទាក់ទងទៅនឹងការបដិសេធតាមទំនើងចិត្តនូវសេរីភាពរបស់អ្នកជាប់ឃុំ-ធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការដាក់ក្នុងមន្ទីរឃុំឃាំង ដែលជនជាប់ចោទនៅក្នុងសំណុំរឿង០០២/០២ ត្រូវបានចោទប្រកាន់ទាក់ទងនឹងមន្ទីរសន្តិសុខស២១[55] ។

37. ដូច្នេះក្រុមមេធាវីការពារក្តីយល់ឃើញថា ការប្រើប្រាស់នូវពេលវេលារបស់ខ្លួនដែលបានបែងចែកកន្លងមក គឺសមស្របតាមច្បាប់ និង សិទ្ធិរបស់ជនជាប់ចោទ ។

## V. សំណើសុំដំណោះស្រាយ

38. ផ្អែកទៅលើសំអាងហេតុដែលបានរៀបរាប់ខាងលើ មេធាវីការពារក្តីសូមស្នើដល់អង្គជំនុំជម្រះសាលាដំបូង៖

ក) ពិចារណាឡើងវិញនូវសេចក្តីសម្រេចរបស់ខ្លួន មិនអនុញ្ញាតពេលវេលាបន្ថែមដល់ក្រុមមេធាវីការពារក្តី ដើមីសួរដេញដោល ប្រាក់ ខន

ខ) កោះហៅ ប្រាក់ ខន សារជាថ្មីដើម្បីឲ្យផ្តល់សក្ខីកម្មទាក់ទងនឹងមន្ទីរសន្តិសុខស២១ និង

គ) ផ្តល់ឲ្យក្រុមមេធាវីការពារក្តីចំនួនបីវគ្គ ដើម្បីបញ្ចប់ការសួរដេញដោល ប្រាក់ ខន

សហមេធាវីការពារក្តី នួន ជា

សុន អរុណ — Victor KOPPE

[54] **D427** ដីកាដំណោះស្រាយ នៅកថាខណ្ឌ៩៥៥ (បញ្ជាក់បន្ថែម)

[55] **D427** ដីកាដំណោះស្រាយ នៅកថាខណ្ឌ១៩០២-១៩០៧ ។ សូមមើលកថាខណ្ឌ១៤ ខាងលើ ។